01034484

E306/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 10 / 2014
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការ បំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

01034485

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់អញ្ញត្រកម្មទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការអនុវត្តការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ដោយមេធាវីការពារក្តីបានអះអាងថា អាជ្ញាយុកាលនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ("ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦") បានហាមឃាត់ការយកមាត្រា ៦ នៃច្បាប់ អ.វ.ត.ក មកអនុវត្ត (ដែលទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ)[1]។ កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានពន្យារពេលពិចារណាលើអញ្ញត្រកម្មនេះ[2]។ មរណភាពរបស់ អៀង សារី នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ បានរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីប្រឆាំងលើរូបគាត់[3]។ កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ក្រោយពីបញ្ចូលបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅក្នុងវិសាលភាពសំណុំរឿង ០០២/០២[4] អង្គជំនុំជម្រះបានអញ្ជើញភាគីនានាក្នុងសំណុំរឿង០០២ ឲ្យបញ្ជាក់ប្រាប់ថា តើខ្លួនយល់ស្របទៅនឹងអញ្ញត្រកម្មដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី ដែរ ឬយ៉ាងណា[5]។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានដាក់សារណានៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ដោយយល់ស្របនឹងអញ្ញត្រកម្មរបស់ អៀង

---

[1] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរ) ឯកសារE43 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

[2] កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា អង្គជំនុំជម្រះបានផ្តល់អាទិភាពលើអញ្ញត្រកម្មទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងការរៀបចំសវនាការ ហើយសេចក្តីសម្រេចលើអញ្ញត្រកម្មដែលសេសសល់នោះ គឺមិនមែនជាឧបសគ្គដល់ការចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២ឡើយ។ *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១" ឯកសារ E141 ទំព័រ ១១។

[3] សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ឯកសារ E270/1 ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[4] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឯកសារ E301/9/1.1 ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ទំព័រ ៦-៧។

[5] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់" ឯកសារ E306 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

សារី[6]។ ការិយាល័យសហព្រះរាជអាជ្ញា (“សហព្រះរាជអាជ្ញា”) បានដាក់ចម្លើយតបកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤[7]។

## ២. សារណា

២. ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានយល់ស្រប និងគាំទ្រលើសំអាងហេតុនៃអញ្ញត្រកម្មរបស់មេធាវីការពារក្តី អៀង សារី ទាក់ទងនឹងយុត្តាធិការ អ.វ.ត.ក ចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[8]។ អនុលោមតាមអញ្ញត្រកម្មនេះ បទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរក្នុងច្បាប់ អ.វ.ត.ក មានអាជ្ញាយុកាល ១០ ឆ្នាំ ដែលមានចែងនៅក្នុងមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[9]។

៣. ទឡ្ហីករណ៍ជាក់លាក់ចំនួនបួន ត្រូវបានលើកឡើងដើម្បីគាំទ្រដល់ជំហរនេះ នៅក្នុងអញ្ញត្រកម្មដើមដំបូងរបស់មេធាវីការពារក្តី អៀង សារី។ ទឡ្ហីករណ៍ទីមួយ មេធាវីការពារក្តីបានលើកឡើងថា ដោយសារតែមាត្រា ៤ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) និងមាត្រា ៥ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) នៃច្បាប់ អ.វ.ត.ក ពិតជាបដិសេធការអនុវត្តអាជ្ញាយុកាលនៃបទល្មើស ខណៈពេលដែលមាត្រា៦ មិនបដិសេធពីការអនុវត្តអាជ្ញាយុកាលនៃបទល្មើសនោះទេ ហេតុដូច្នេះអាជ្ញាយុកាលនៃបទល្មើសត្រូវតែយកមកអនុវត្តចំពោះមាត្រា៦[10]។ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍នេះ មេធាវីការពារក្តីបានលើកឡើងថា អ.វ.ត.ក គឺជាតុលាការកម្ពុជា ហើយច្បាប់ អ.វ.ត.ក បានបញ្ចូលប្រកប

---

[6] ជំហររបស់ នួន ជា លើអញ្ញត្រកម្មសេសសល់ដែលក្រុមមេធាវីការពារក្តីបានលើកឡើង ឯកសារ E306/1 ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៤។ *សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ* ឯកសារ E306/2 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

[7] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផន ស្តីពីអញ្ញត្រកម្ម ឯកសារ E306/4 ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤។

[8] ជំហរទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ដែលលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី ឯកសារ E306 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ១, ៣។ *សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ* ឯកសារ E306/2 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ៩-១៣។

[9] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពីបំពារបំពានធ្ងន់ធ្ងរ) ឯកសារ E43 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ១។ មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[10] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពីបំពារបំពានធ្ងន់ធ្ងរ) ឯកសារ E43 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ១-២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៨៦។

ដោយប្រសិទ្ធិភាព នូវបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវទៅក្នុងច្បាប់កម្ពុជា ដែលអនុវត្តនូវអាជ្ញាយុកាលនៃបទល្មើស លើកលែងតែមានចែងផ្សេងពីនេះ[11]។ ទឡ្ហីករណ៍ទីពីរ ផ្អែកតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បទឧក្រិដ្ឋ គឺជាបទល្មើសមួយដែលត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារជាអប្បបរមាចំនួន ៥ ឆ្នាំ។ ដោយសារតែបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ក៏អនុវត្តទោសជាប់ពន្ធនាគារជាអប្បបរមាចំនួន ៥ ឆ្នាំផងដែរ ហេតុដូច្នេះ មេធាវីការពារក្តីលើកឡើងថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រូវតែចាត់ទុកជាបទឧក្រិដ្ឋដែលមានអាជ្ញាយុកាល[12]។ ទឡ្ហីករណ៍ទីបី មេធាវីការពារក្តីបានលើកឡើងថា អាជ្ញាយុកាលនៃបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរ មិនអាចពន្យារពេលបាននោះទេ ដោយសារតែវានឹងរំលោភបំពានលើគោលការណ៍គ្មានប្រតិសកម្មនៃច្បាប់។ លើសពីនេះទៀត ច្បាប់ អ.វ.ត.ក បានចែងច្បាស់អំពីការពន្យារអាជ្ញាយុកាលនៃបទល្មើស តែក្នុងករណីទាក់ទងនឹងបទល្មើសជាតិនៅក្នុងមាត្រា ៣ ប៉ុណ្ណោះ[13]។ ជាចុងក្រោយ មេធាវីការពារក្តីលើកឡើងថា ប្រព័ន្ធច្បាប់កម្ពុជាយកគំរូពីប្រព័ន្ធច្បាប់បារាំង ដែលបានអនុវត្តយ៉ាងជាក់លាក់នូវអាជ្ញាយុកាលចំពោះបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិវិញ គឺមិនមានអាជ្ញាយុកាលនោះទេ ហើយច្បាប់ អ.វ.ត.ក ត្រូវបានព្រាងដោយយកគំរូតាមវិធីសាស្ត្ររបស់ប្រទេសបារាំងទាក់ទងនឹងករណីនេះ[14]។

៤. មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងបន្ថែមទៀតនូវទឡ្ហីករណ៍ដែលទាក់ទងនឹងប្រព័ន្ធច្បាប់បារាំង។ មេធាវីការពារក្តីលើកឡើងថា នៅឆ្នាំ ២០១០ ភាពខុសគ្នារវាងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងច្បាប់បារាំង ហើយបានបន្ថែម

---

[11] *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៨៦-៨៧។

[12] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពីបំពារបំពានធ្ងន់ធ្ងរ) ឯកសារ E43 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២។

[13] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពីបំពារបំពានធ្ងន់ធ្ងរ) ឯកសារ E43 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១-៧។

[14] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពីបំពារបំពានធ្ងន់ធ្ងរ) ឯកសារ E43 ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៨។

ចិរវេលាកំណត់អាជ្ញាយុកាលនៃឧក្រិដ្ឋកម្មសង្គ្រាមទៀតផង[15]។ មេធាវីការពារក្តីក៏នៅតែលើកឡើងថា បទប្បញ្ញត្តិអំពីអាជ្ញាយុកាលនៃបទល្មើស ក៏មិនមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវនោះទេ[16] ហើយការហាមមិនឱ្យអនុវត្តអាជ្ញាយុកាលនៃបទល្មើសនេះ មិនមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះឡើយ[17]។

៥. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អនុសញ្ញាទីក្រុងហ្សឺណែវ និងច្បាប់ អ.វ.ត.ក មិនបានចែងអំពីការបង្កើតអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់លើការបំពារបំពារយ៉ាងធ្ងន់ធ្ងរឡើយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា មិនមានអាជ្ញាយុកាលណាមួយ រារាំងដល់ការអនុវត្តបទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរចំពោះជនជាប់ចោទឡើយ[18]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានបន្ថែមទៀតថា (i) មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ អនុវត្តបានចំពោះតែបទឧក្រិដ្ឋធ្ងន់ធ្ងរធម្មតាប៉ុណ្ណោះ ("បទឧក្រិដ្ឋ") គឺមិនមែនចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ដែល អ.វ.ត.ក មានយុត្តាធិការនោះទេ (ii) ច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ចែងថា អាជ្ញាយុកាលនៃបទល្មើស មិនអាចយកមកអនុវត្តចំពោះបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរឡើយ ហើយ (iii) ការអនុញ្ញាតឱ្យអនុវត្តអាជ្ញាយុកាលលើបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរ នឹងធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការចោទប្រកាន់ចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរ[19]។

---

[15] *សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ* ឯកសារ E306/2 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ៩-១២ ដែលយោងលើច្បាប់លេខ ២០១០-៩៣០ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលច្បាប់ព្រហ្មទណ្ឌឱ្យស្របទៅនឹងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧។

[16] *សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ* ឯកសារ E306/2 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ១៣។

[17] *សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ* ឯកសារ E306/2 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ១៣។

[18] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផន ស្តីពីអញ្ញត្រកម្ម ឯកសារ E306/4 ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៩៧-១១៥ (ភាសាអង់គ្លេស)។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩ ឯកសារ E51/5/3/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៩។

[19] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/17 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ២០២-២០៥។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩ ឯកសារ E51/5/3/1

៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់សេចក្តីសន្និដ្ឋានថ្មីៗចុងក្រោយដើម្បីបញ្ជាក់បំភ្លឺ អំពីជំហររបស់ពួកគេលើបញ្ហានេះទេ។ ដូច្នេះ អង្គជំនុំជម្រះផ្អែកលើទឡ្ហីករណ៍ មុនៗរបស់ពួកគេ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា[20] ហើយបានអះអាងថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវមិនកំណត់អំពីអាជ្ញាយុកាលនោះទេ[21]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា លក្ខណៈ*បទដ្ឋានដាច់ខាត*នៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងកាតព្វកិច្ចក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មទាំងនេះមានន័យថា បទប្បញ្ញត្តិនៃអាជ្ញាយុកាលក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ មិនអាចយកមកអនុវត្តចំពោះបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរនោះឡើយ[22]។

## ៣. សំអាងហេតុ

៧. អនុលោមតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ដែលមិនមានការជំទាស់តវ៉ាពីភាគីឡើយ។ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ គឺជាបទល្មើសដែលស្ថិតនៅក្នុងច្បាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[23]។ មាត្រា ៦ មិនបានបង្កើតឲ្យមានឧក្រិដ្ឋកម្មថ្មីមួយនោះទេ ប៉ុន្តែគ្រាន់តែផ្តល់យុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក តែប៉ុណ្ណោះ[24]។

---

ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៨-២១។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផន ស្តីពីអញ្ញត្រកម្ម ឯកសារ E306/4 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ៣-៦។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៩៧-១១៥ (ភាសាអង់គ្លេស)។

[20] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៤ (ភាសាអង់គ្លេស)។

[21] ចម្លើយតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណារបស់ក្រុមភាគីការពារក្តីទាក់ទងនឹងអញ្ញត្រកម្មបឋម (វិធាន ៨៩) ឯកសារ E51/5/4 ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ៥៣។

[22] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ១៣។

[23] សាលក្រម *កាំង ហ្គេកអ៊ាវ* ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤០៦ និង ៤០៨ ដែលអង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរថា ជនជាប់ចោទអាចប្រមើលមើលឃើញនៅក្នុងរឿងក្តីនេះផងដែរថា គាត់អាចត្រូវបានចាប់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើទាំងឡាយដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។

[24] មាត្រា ៦ ចែងដូចខាងក្រោម៖

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដូចជាអំពើប្រឆាំងមនុស្ស ឬ ទ្រព្យសម្បត្តិ ដែលត្រូវ

៨. អង្គជំនុំជម្រះសាលាដំបូង រំឭកឡើងវិញថា អ.វ.ត.ក អាចអនុវត្តបានចំពោះតែបទប្បញ្ញត្តិទាំងឡាយណាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលមានចែងជាក់លាក់នៅក្នុងច្បាប់ អ.វ.ត.ក តែប៉ុណ្ណោះ។ បទប្បញ្ញត្តិយោងតែមួយគត់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលមានចែងនៅក្នុងមាត្រា ៣ នៃច្បាប់ អ.វ.ត.ក[25]។ មាត្រា ៣ មិនបានអនុញ្ញាតឱ្យអនុវត្តដោយផ្ទាល់នូវក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទាំងស្រុងនោះឡើយ ប៉ុន្តែបានដាក់បញ្ចូលបទល្មើសជាតិជាក់លាក់មួយចំនួននៅក្នុងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក។ មាត្រា ៣ មិនបានកំណត់ពីអាជ្ញាយុកាលចំពោះការចោទប្រកាន់លើឧក្រិដ្ឋកម្មអន្តរជាតិ ដែលមិនពាក់ព័ន្ធនឹងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ឬមិនបានលើកឡើងអំពីបញ្ហានេះទេ។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មិនបានកម្រិត ឬមិនបានអះអាង

---

ការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩៖

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព
- ការបំផ្លាញ ឬ ធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការបង្ខំឱ្យឈ្លើយសឹក ឬ ជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់
- ការនិរទេស ការជន្លៀស ឬ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការយកជនស៊ីវិលជាចំណាប់ខ្មាំង។

[25] មាត្រា ៣ នៃច្បាប់ អ.វ.ត.ក ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩៖

- មនុស្សឃាត មាត្រា ៥០១ ៥០៣ ៥០៤ ៥០៥ ៥០៦ ៥០៧ និងមាត្រា ៥០៨
- ទារុណកម្ម មាត្រា ៥០០
- ការវាយប្រហារលើសាសនា មាត្រា ២០៩ និងមាត្រា ២១០។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ។

ទោសប្បញ្ញត្តិចែងក្នុងមាត្រា ២០៩ ៥០០ ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវកំណត់ថាអតិបរិមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា ៣៨ និងមាត្រា ៣៩ ថ្មី នៃច្បាប់នេះ។

ថា បានកម្រិតការចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមដែលមានប្រភពមកពីច្បាប់អន្តរជាតិឡើយ និងដែលបានយោងជាក់លាក់ដោយច្បាប់ អ.វ.ត.ក ថាជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឡើយ។ ហេតុដូច្នេះ ការចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលដែល អ.វ.ត.ក មានយុត្តាធិការពេលវេលា គឺបានផ្អែកទាំងស្រុងលើច្បាប់អន្តរជាតិ មិនមែនតែលើនិយមន័យនៃឧក្រិដ្ឋកម្មបែបនេះទេ ប៉ុន្តែថែមទាំងលើការកំណត់អំពីអាជ្ញាយុកាលជាធរមានផងដែរ[26]។ អនុសញ្ញាទីក្រុងហ្សឺណែវ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនបានកំណត់ពីអាជ្ញាយុកាលលើការចោទប្រកាន់អំពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរឡើយ[27]។

---

[26] *សូមមើល* រឿងក្តី *Kononov ទល់នឹង Latvia* តុលាការសិទ្ធិមនុស្សអឺរ៉ុប (ពាក្យបណ្តឹងលេខ 36376/04) សាលក្រម ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ២២៨-២៣៣ ដែលដោះស្រាយអំពីស្ថានភាពស្រដៀងគ្នា។

[27] ទោះបីជាមាត្រា II(៥) នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ លើកឡើងអំពីបញ្ហាទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាមដែលបានប្រព្រឹត្តឡើងនៅលើទឹកដីអាល្លឺម៉ង់នៅមុន និងក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទី២ ក៏ដោយ ("ជនជាប់ចោទពុំត្រូវទទួលបានផលប្រយោជន៍នៃអាជ្ញាយុកាលឡើយ") ក៏ពុំមានបទប្បញ្ញត្តិចែងយោងលើអាជ្ញាយុកាលណាមួយសម្រាប់ការចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិនៅញូរ៉មប៊ឺក/តូក្យូ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឬគោលការណ៍ញូរ៉មប៊ឺកនោះទេ។ ផ្ទុយមកវិញ ក្នុងការឆ្លើយតបទៅនឹងការភ័យខ្លាចដែលបានបង្ហាញថា ឧក្រិដ្ឋជនសង្គ្រាមដូចបានចោទប្រកាន់អាចគេចផុតពីការចោទប្រកាន់ដោយសារការផុតអាជ្ញាយុកាលនោះ មហាសន្និបាតនៃអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាចុះខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អនុសញ្ញានេះចូលជាធរមាននៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧០ និងកិច្ចខិតខំក្នុងការធានាឲ្យបាននូវការចោទប្រកាន់ប្រកបដោយប្រសិទ្ធភាពចំពោះឧក្រិដ្ឋជនសង្គ្រាមក៏ត្រូវបានគាំទ្រតាមរយៈអនុសញ្ញាអឺរ៉ុបស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ នៅក្នុងរឿងក្តី *Kononov ទល់នឹង Latvia* តុលាការសិទ្ធិមនុស្សអឺរ៉ុប បានធ្វើការវិភាគលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយបានសម្រេចថា ច្បាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៤៤ ពុំមានចែងអំពីបញ្ហាអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមនោះទេ។ ផ្អែកតាមការពិនិត្យមើលឡើងវិញនេះ តុលាការនេះបានសន្និដ្ឋានថា "គ្មានអាជ្ញាយុកាលត្រូវបានកំណត់នៅក្នុងច្បាប់អន្តរជាតិទាក់ទងនឹងការចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមនោះឡើយ" ហើយការវិវឌ្ឍនៅក្នុងច្បាប់អន្តរជាតិតាំងពីឆ្នាំ ១៩៩៤ ពុំបានកំណត់អាជ្ញាយុកាលចំពោះបទចោទនៃឧក្រិដ្ឋកម្មសង្គ្រាមឡើយ៖ រឿងក្តី *Kononov ទល់នឹង Latvia* តុលាការសិទ្ធិមនុស្សអឺរ៉ុប (ពាក្យបណ្តឹងលេខ 36376/04) សាលក្រម ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ២៣១-២៣៣។ ជំហរនេះក៏ឃើញឆ្លុះបញ្ចាំងនៅក្នុងការសិក្សារបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ស្តីពីច្បាប់ទំនៀមទម្លាប់មនុស្ស-ធម៌អន្តរជាតិផងដែរ ដែលបានរកឃើញថា វាជានិយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលថា អាជ្ញាយុកាលមិនអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មសង្គ្រាមនោះទេ៖ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ *ច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ វ៉ុលលូម I: វិធានវិធាន* ១៦០ និងការអនុវត្តដែលជាមូលដ្ឋាគាំទ្រផ្សេងទៀតនៅ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ *ច្បាប់ទំនៀមទម្លាប់ មនុស្សធម៌អន្តរជាតិ វ៉ុលលូម II: ការអនុវត្ត* ការអនុវត្តទាក់ទងនឹងវិធាន ១៦០៖ អាជ្ញាយុកាល។ អង្គជំនុំជម្រះយល់ឃើញថា ជំហររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិអាចជឿជាក់បាន និងជាការឆ្លុះបញ្ចាំងយ៉ាងសេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើ

នៅក្នុងករណី មិនមានកំណត់អំពីយុត្តាធិការឲ្យបានច្បាស់លាស់នៅក្នុងច្បាប់ អ.វ.ត.ក ឬនៅក្នុងច្បាប់អន្តរជាតិបែបនេះ ទឡ្ហីករណ៍នេះគឺគ្មានមូលដ្ឋានសំអាងឡើយ។

៩. ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា ភាពខុសគ្នានៅក្នុងសេចក្តីព្រាងបទប្បញ្ញត្តិក្នុងច្បាប់ អ.វ.ត.ក គាំទ្រដល់ទស្សនៈដែលយល់ឃើញថា អាជ្ញាយុកាលនៃបទល្មើសត្រូវតែអនុវត្តចំពោះបទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរ។ ក្រោយពីពិចារណាចំណុចខាងលើ ទោះបីជាមាត្រា ៤ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) និងមាត្រា ៥ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) បានចែងយ៉ាងច្បាស់លាស់ និងដោយឡែកពីគ្នាថា ឧក្រិដ្ឋកម្មទាំងនេះ "គ្មានអាជ្ញាយុកាលក៏ដោយ" ក៏អង្គជំនុំជម្រះ ជឿជាក់ថា ការដែលមិនមានចែងដូច្នោះនៅក្នុងមាត្រា ៦ មិនត្រូវឲ្យមានការសន្និដ្ឋានផ្ទុយពីនេះឡើយ។

១០. ក្រុមមេធាវីការពារក្តីសន្និដ្ឋានបន្ថែមទៀតថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រូវប្រៀបប្រដូចនឹងបទឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ ដែលត្រូវយកអាជ្ញាយុកាលតាមច្បាប់ជាតិមកអនុវត្ត។ ការសន្និដ្ឋាននេះគឺបានផ្អែកលើនិយមន័យនៃបទឧក្រិដ្ឋ អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលជាបទល្មើសមួយត្រូវទទួលទោសជាប់ពន្ធនាគារអប្បបរមារយៈពេល ៥ ឆ្នាំ ហើយនឹងបានផ្អែកលើករណីដែលថា បទល្មើសការបំពារបំពានយ៉ាងធ្ងន់ធ្ងរ អនុលោមតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ត្រូវទទួលទោសជាប់ពន្ធនាគារអប្បបរមារយៈពេល ៥ ឆ្នាំ ដូចគ្នា។ ទឡ្ហីករណ៍នេះ មិនអាចជឿជាក់បានឡើយ។ អង្គជំនុំជម្រះសូមរំឭកឡើងវិញថា មាត្រា ៦ បានផ្តល់យុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរដែលកើតមានរួចហើយតែប៉ុណ្ណោះ។ ឧក្រិដ្ឋកម្មអន្តរជាតិមានអត្ថិភាពនៅក្រៅក្របខណ្ឌនៃច្បាប់ជាតិ ជាឧទាហរណ៍ ក្របខណ្ឌនៃច្បាប់ជាតិនេះបានចាត់ថ្នាក់អំពើនានាថាជា បទឧក្រិដ្ឋ ឬ បទមជ្ឈិម។ ភាពស្រដៀងគ្នានៃទោសជាប់ពន្ធនាគារអប្បបរមានេះ មិនអាចប្រដូចការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិបាននោះទេ។

---

ត្រឹមត្រូវអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាននៅចន្លោះឆ្នាំ១៩៩៤ និងសព្វថ្ងៃ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំមានចែងអំពីអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ នោះទេ។ ជាយថាហេតុ គេអាចកត់សម្គាល់ឃើញថា ច្បាប់ជាតិនានា រួមទាំងច្បាប់កម្ពុជាផងដែរនោះ បានប្រមើលមើលឃើញយ៉ាងច្បាស់តាំងពីពេលនោះមកថា ឧក្រិដ្ឋកម្មសង្គ្រាម "ពុំអាចផុតអាជ្ញាយុកាល" សូមមើល មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ ការអនុម័តបទប្បញ្ញត្តិចុងក្រោយនេះបង្ហាញឲ្យឃើញថា ទោះបីជាច្បាប់កម្ពុជាអាចមានទំនាក់ទំនងខ្លះជាមួយនឹងច្បាប់បារាំងក៏ដោយ ក៏ច្បាប់នេះបានបង្កើតឡើងក្នុងវិធីមួយផ្សេងពីវិធីសាស្ត្ររបស់បារាំង។

១១. អង្គជំនុំជម្រះពិចារណាឃើញថា សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីដែលបានលើកឡើងថា ច្បាប់ អ.វ.ត.ក ត្រូវបានព្រាងឡើងតាមលំនាំប្រព័ន្ធច្បាប់បារាំង ដែលបានកំណត់ពីអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ក៏មិនអាចជឿជាក់បានដែរ។ ក្របខណ្ឌគតិយុត្តពិសេសរបស់ អ.វ.ត.ក ចែងអំពីយុត្តាធិការរបស់ អ.វ.ត.ក ខ្លួនឯង។ ក្រុមមេធាវីការពារក្តី ខកខានមិនបានផ្តល់ភ័ស្តុតាងគាំទ្រ ថាតើទិដ្ឋភាពនៃគំរូច្បាប់បរទេសត្រូវអនុវត្តបានដោយរបៀបណា ក្នុងករណីដែលមិនមានបទប្បញ្ញត្តិជាក់លាក់ចែងបញ្ចូលនៅក្នុងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក នោះ។

១២. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា មិនមានអាជ្ញាយុកាលដែលអាចអនុវត្តបានចំពោះបទប្បញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅក្នុងច្បាប់ អ.វ.ត.ក ឡើយ[28]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខ្លួនមិនចាំបាច់ត្រូវសម្រេច ថាតើការពន្យារអាជ្ញាយុកាលអាចធ្វើទៅបានដែរ ឬ យ៉ាងណានោះទេ។

**ផ្អែកតាមសំអាងហេតុ ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**សម្រេចបដិសេធ** អញ្ញត្រកម្មរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ទាក់ទងនឹងអាជ្ញាយុកាលលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**

---

[28] ករណីនេះគឺស្របគ្នាជាមួយនឹងការសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះថា "[អ]នុសញ្ញាទីក្រុងហ្សឺណែវដែលជាច្បាប់អាចអនុវត្តបានក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ចែងថា ឧក្រិដ្ឋកម្មសង្គ្រាមពុំមានអាជ្ញាយុកាលនោះទេ ដែលបង្ហាញថា ពុំមានអាជ្ញាយុកាលដែលអាចអនុវត្តបានទេ។ ការលើកឡើងផ្ទុយពីនេះពុំទុកជាបានការឡើយ។ ដោយសារតែម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានធ្វើការជំទាស់ផ្នែកយុត្តាធិការ មូលដ្ឋាននេះពុំអាចទទួលយកបានទេ"៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៧៣។